**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**
លេខ: ១៣១៤.សណ

ថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
កណ្តាល ថ្ងៃទី០៤ ខែ១០ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២៤

**យោង÷** លិខិតលេខ ០៧៦ស.ជ.ណ/គ.ជ.អ.ប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ស្តីពី សេចក្តីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៤។

រដ្ឋបាលខេត្តកណ្តាល នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២៤ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០២៤។ អ្នកទទួលការដែលមានក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ប្រភេទ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អគារ និងការងារបេតុង...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី(ប្រឡាយ ទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវជីស ផ្លូវក្រួសក្រហម លូមូល...។ល។)
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច០២ ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំ ក្នុងអំឡុងពេល០៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងចុះពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះ **រហូតដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង១៧ និង៣០នាទីរសៀល។** ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះ អ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្តកណ្តាល ដោយឥតបង់ថ្លៃ ដែលមានទីតាំងនៅអគារC ក្នុងបរិវេណសាលាខេត្តកណ្តាល៕

<u>ចម្លងជូន</u> ៖
- ក្រសួងមហាផ្ទៃ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត (ដើម្បីគោរពជូនជ្រាប)
- ឯកសារ កាលប្បវត្តិ

**អភិបាលខេត្ត**

**គង់ សោភ័ណ្ឌ**

អាសយដ្ឋាន ផ្លូវជាតិលេខ ២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ០២៣ ៤២ ៥៥ ៥៨ ទូរសារ ០២៣ ៤២ ៥៥ ៥៥ សារអេឡិចត្រូនិច admin@kandal.gov.kh
Address: NR 2. Doem Mean Village. Doem Mean Commune. Takhmao Town. Kandal Province. Cambodia. Tel: 023 42 55 58 Fax: 023 42 55 55 Email: admin@kandal.gov.kh